**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

**National - Religion - King**

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

**No ០៨០៨ MOC / SM 2009**

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩

# <u>សេចក្តីជូនដំណឹង</u>

គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា សូមជំរាប ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអគ្គនាយក អគ្គនាយិកា នៃ ស្ថានីយ៍ ទូរទស្សន៍-ទូរទស្សន៍ខ្សែកាប ជ្រាបថា កន្លងមក គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា បានសង្កេតឃើញថា នៅតាមបណ្តាស្ថានីយ៍ ទូរទស្សន៍-ទូរទស្សន៍ខ្សែកាប មួយចំនួនបានចាក់ផ្សាយចម្រៀងខារ៉ាអូខេ ខ្សែភាពយន្ត-វីដេអូ ដែលជាប្រភេទឌីសថតចម្លងខុសច្បាប់ ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ឬ អ្នកទទួលសិទ្ធិបន្ត ដែលធ្វើអោយម្ចាស់សិទ្ធិខាតបង់ផលប្រយោជន៍ធ្ងន់ធ្ងរ ដែលទង្វើបែបនេះ៖

-ផ្ទុយទៅនឹងមាត្រា ១៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលចែងថា អ្នកនិពន្ធស្នាដៃ ជាអ្នកទទួលបានសិទ្ធិជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះ ហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវទទួលស្គាល់ និងមាត្រា ២១ (ឈ) ដែលចែងថា អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខធ្វើដោយខ្លួនឯង ឬ អនុញ្ញាតអោយគេធ្វើនូវការផ្សាយស្នាដៃតាមអង្គភាពទូរផ្សាយ ។

-ផ្ទុយទៅនឹងប្រកាសលេខ ៦០ ប្រកវវស ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៣ ស្តីពី ការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាព ដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រង់ប្រការ៤ ដែលចែងថា រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលបាននូវសិទ្ធិស្របច្បាប់លើស្នាដៃ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃ ហើយទទួលបាននូវសិទ្ធិ ធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃរបស់ខ្លួន និងប្រការ៥ ចែងថារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបាននូវសិទ្ធិស្របច្បាប់លើស្នាដៃមានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃ ហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និង សិទ្ធិការពារលើស្នាដៃនោះ ។

ទង្វើបែបនេះត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល កថាខណ្ឌទី៣ ចែងថា ការចាក់ផ្សាយតាមទូរផ្សាយ ដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬ ពី ផលិតករវីដេអូ ឬ អង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និង ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយខែ) ដល់ ៣(បីខែ) ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។

អាស្រ័យហេតុនេះ ដើម្បីលើកទឹកចិត្តដល់ម្ចាស់ស្នាដៃក្នុងការបង្កើតស្នាដៃថ្មីៗក្នុងគោលបំណងទ្រទ្រង់វិស័យ សិល្បៈវប្បធម៌ ឱ្យឋិតនៅគង់វង្សយូរអង្វែង លើកស្ទួយសេដ្ឋកិច្ច និងកេរ្តិ៍ឈ្មោះរបស់ប្រទេសជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា សូមជូនដំណឹងដល់បណ្តាស្ថានីយ៍ ទូរទស្សន៍-ទូរទស្សន៍ខ្សែកាប ទាំងអស់ត្រូវបញ្ឈប់ជាបន្ទាន់ នូវរាល់ការចាក់ផ្សាយ ចម្រៀងខារ៉ាអូខេ ខ្សែភាពយន្ត-វីដេអូ រូបភាពជាឈុតផ្សេងៗដែលគ្មានអជ្ញាប័ណ្ណ ឬការអនុញ្ញាត ពីម្ចាស់សិទ្ធិចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

គណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា មានសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជា អគ្គនាយក អគ្គនាយិកា ស្ថានីយ៍ ទូរទស្សន៍-ទូរទស្សន៍ខ្សែកាប ទាំងអស់នឹងសហការជាមួយគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្នុងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ឱ្យមានប្រសិទ្ធិភាព ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា**

**ចម ប្រសិទ្ធ**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-សមាជិកគណៈកម្មាធិការជាតិ គ្រប់គ្រងកម្មសិទ្ធិបញ្ញា
-ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ លោក ឈឹម ទីណា